ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**Royaume du Cambodge**
**Nation Religion Roi**

**Kingdom of Cambodia**
**Nation Religion King**

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

**ឯកសារដើម**
~~ORIGINAL DOCUMENT/DOCUMENT~~ ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 23 / 12 / 2009
ម៉ោង (Time/Heure): 10:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**
**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

**សំណុំរឿងលេខ ៖ 002/19-09-2007-អ.វ.ត.ក.-ក.ស.ច.ស.**

| | |
|---|---|
| ចំពោះមុខ ៖ | ចៅក្រម យូ ប៊ុនឡេង |
| | ចៅក្រម Marcel LEMONDE (ម៉ាសែល ឡឺម៉ុង) |
| កាលបរិច្ឆេទ៖ | ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០០៩ |
| ភាសាដើម៖ | ខ្មែរ /អង់គ្លេស |
| ចំណាត់ថ្នាក់ឯកសារ៖ | សាធារណៈ |

# ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំដាក់ឯកសារនានាដែលមាននៅក្នុងសំណុំរឿងលេខ០០១ ចូលក្នុងសំណុំរឿងលេខ០០២

**សហព្រះរាជអាជ្ញា**

អ្នកស្រី ជា លាង
លោក Andrew CAYLEY

**ជនត្រូវចោទ**

នួន ជា — ខៀវ សំផន
អៀង សារី — កាំង ហ្គេកអ៊ាវ ហៅ ឌុច
អៀង ធីរិទ្ធ

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

 នី ចាន់ឌី — ឡោ ជុនធី — Pierre-Olivier SUR
គង់ ពិសី — ហុង គីមសួន — Mahdev MOHAN
យុង ផានិត — គីម ម៉េងឃី — Olivier BAHOUGNE
មុំ សុវណ្ណារី — ស៊ីន សុវ៉ន — David BLACKMAN
ជេត វណ្ណលី — ពេជ អង្គ — Martine JACQUIN
Silke STUDZINSKY — Annie DELAHAIE
Phillipe CANONNE — Fabienne TRUSSES-NAPROUS
Elizabeth Rabesandratana — Patrick BAUDOIN
Lyma Thuy Nguyen
Marie Guiraud

**មេធាវីការពារក្តី**

សុន អរុណ — Michiel PESTMAN
Victor KOPPE
អាង ឧត្តម — Michael G. KARNAVAS
ផាត់ ពៅសៀង — Diana ELLIS
ស សុវ៉ាន — Jacques VERGES
ការ សាវុត្ថ — François ROUX
Marie-Paule CANIZARES

**ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 23 / 12 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

យើង **យូ ប៊ុនឡេង** និង Marcel LEMONDE (ម៉ាសែល ឡឺម៉ុង) សហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក.")

បានឃើញច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ ("ច្បាប់ស្តីពី អ.វ.ត.ក")

បានឃើញការបន្តការស៊ើបសួរលើឈ្មោះ **នួន ជា** (NUON Chea) និង **ជនដទៃ** ដែលត្រូវបានដាក់ឱ្យស្ថិតក្រោមការពិនិត្យលើ**បទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ការបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ការធ្វើមនុស្សឃាត ការធ្វើទារុណកម្ម ការវាយប្រហារលើសាសនា** បទល្មើសដែលមានចែង និងផ្តន្ទាទោស តាមមាត្រា៣ មាត្រា៤ មាត្រា៥ មាត្រា៦ មាត្រា២៩ (ថ្មី) និងមាត្រា៣៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ២០៩ មាត្រា ២១០ មាត្រា ៥០០ មាត្រា ៥០១ មាត្រា ៥០៣ ដល់ មាត្រា ៥០៨ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦

បានឃើញវិធាន៥៥(១០) នៃវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញ ("វិធានផ្ទៃក្នុង")

បានឃើញសំណើរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០០៩ ("សំណើ" D288)

## សំណើរបស់សហព្រះរាជអាជ្ញា

១. នៅក្នុងសំណើដែលបានលើកឡើងខាងលើ សហព្រះរាជអាជ្ញាស្នើឱ្យមានការបញ្ជូនឯកសារដាក់ចូលក្នុងសំណុំរឿងលេខ០០២ "*ឯកសារសំខាន់ៗទាំងអស់ (រួមទាំងកំណត់ហេតុ ជាលាយលក្ខណ៍អក្សរ ការដាក់ឯកសារ ភស្តុតាង និងប្រតិចារិក ដែលត្រូវបានចាត់ចំណាត់ថ្នាក់ ជាឯកសារសាធារណៈឬជាឯកសារសម្ងាត់) ដែលត្រូវបានដាក់នៅក្នុងសំណុំរឿងលេខ០០១ ចាប់តាំងពីពេលបញ្ជូនសំណុំរឿងទៅអង្គជំនុំជម្រះសាលាដំបូងមកម្ល៉េះ ...*" ក៏ដូចជា "ឯកសារទាំងអស់ ដែលមាននៅក្នុងប្រភេទសំណុំឯកសាររង D25" - ពោលគឺ ឯកសារនានាដែលពាក់ព័ន្ធនឹងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ទាំងអស់នៅក្នុងសំណុំរឿងលេខ០០១។

## មូលហេតុសម្រាប់សេចក្ដីសម្រេច

២. មានការទទួលស្គាល់ដោយសហព្រះរាជអាជ្ញាថា ឯកសារសំខាន់ៗទាំងអស់ដែលសហចៅក្រមស៊ើបអង្កេតបានដាក់នៅក្នុងសំណុំរឿងលេខ០០១ តាំងពីការបញ្ជូនសំណុំរឿងទៅអង្គជំនុំជម្រះសាលាដំបូងនោះ ត្រូវបានដាក់ចូលក្នុងសំណុំរឿងលេខ០០២ រួចហើយ តាមរយៈការចេញដីកាសម្រេច ជាធរមាន ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៨ ដែលធ្វើដោយសហចៅក្រមស៊ើបអង្កេត - ឯកសារ D108[1]។ ដូចនេះ សហព្រះរាជអាជ្ញាបានលើកឡើងថា ដើម្បីជាប្រយោជន៍នៃ *"ភាពងាយស្រួល ការមានឯកសារពេញលេញ និងការយោងដែលងាយស្រួលជាងនេះ ច្បាប់ចម្លងនៃឯកសារទាំងអស់នេះគួរតែត្រូវបានបញ្ចូលនៅក្នុងការផ្ទេរនេះផងដែរ"*[2]។ ប៉ុន្តែសហចៅក្រមស៊ើបអង្កេតយល់ឃើញថា វាមិនមែនជារឿងសមស្របក្នុងការចម្លងឯកសារនានាដ៏ច្រើនលើសលុបទាំងនោះនោះទេ ដោយហេតុថា ឯកសារទាំងអស់ដែលប្រមូលបាននៅក្នុងពេលស៊ើបអង្កេតនៅក្នុងសំណុំរឿងលេខ០០១ (ក្រៅតែពីពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី) ត្រូវបានដាក់ចូលក្នុងសំណុំរឿងលេខ០០២ រួចហើយ។

៣. លើសពីនេះទៀត ដូចដែលបានលើកឡើងម្យ៉ាងទៀតដោយសហព្រះរាជអាជ្ញា សហចៅក្រមស៊ើបអង្កេតបានពិចារណាឃើញថា វាមិនមានភាពចាំបាច់ដើម្បី "ធ្វើបច្ចុប្បន្នភាព"[3] ឯកសារណាមួយក្នុងចំណោមឯកសារទាំងអស់នេះ តាមរយៈអង្គភាពបណ្ណសារ សម្រាប់គោលបំណងនៃសំណើនេះឡើយ នៅពេលដែលឯកសារទាំងនោះត្រូវបានរៀបរាប់យ៉ាងល្អិតល្អន់នៅក្នុងតារាងសង្ខេប ដែលបានភ្ជាប់ជាឧបសម្ព័ន្ធទៅនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតនោះ - ឯកសារ D108.1។

៤. ពាក់ព័ន្ធទៅនឹងពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីទាក់ទិននឹងសំណុំរឿងលេខ១ ដែលត្រូវបានដកចេញពីការផ្ទេរឯកសារ D108 សហចៅក្រមស៊ើបអង្កេតពិចារណាឃើញថា ទោះបីជាគ្មានវិធានការការពារត្រូវបានបង្គាប់ពាក់ព័ន្ធនឹងពាក្យសុំទាំងអស់នេះក៏ដោយ វានៅតែមិនសមស្រប

---

[1] សំណើ - កថាខណ្ឌទី២។

[2] ដូចជើងទំព័រខាងលើ - កថាខណ្ឌទី៧។

[3] ដូចជើងទំព័រខាងលើ - កថាខណ្ឌទី៧។

និងមិនចាំបាច់ក្នុងការដាក់ឯកសារពាក្យសុំទាំងអស់នេះ[4] ចូលក្នុងសំណុំរឿងលេខ០០២ នោះដែរ។ បុគ្គលនានាដែលបានដាក់ពាក្យសុំចូលរួមក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងសំណុំរឿងលេខ ០០១ ត្រូវបានទទួលយកដោយហេតុថា ពួកគាត់បានលើកឡើងនូវព្យសនកម្ម ដោយផ្ទាល់និងមានលក្ខណៈផ្ទាល់ខ្លួន ពាក់ព័ន្ធទៅនឹងវិសាលភាពអង្គហេតុ (*in rem scope*) នៃការស៊ើបអង្កេតប្រឆាំងនឹងជនត្រូវចោទ។ ឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីនេះមិនអាចផ្ទេរទៅកិច្ចដំណើរការនីតិវិធីមួយផ្សេងទៀតបានទេ

លើកលែងតែអ្នកដាក់ពាក្យបានបង្ហាញនូវគោលបំណងចូលរួមក្នុងសំណុំរឿងលេខ០០២ នៅក្នុងឯកសារជាលាយលក្ខណ៍អក្សរ។ ចំនួននៃដើមបណ្តឹងរដ្ឋប្បវេណីគួរឲ្យកត់សម្គាល់ នៅក្នុងសំណុំរឿងលេខ០០១ ដែលពាក្យសុំរបស់ពួកគាត់ ក៏អាចត្រូវបានទទួលយកផងដែរ សម្រាប់គោលបំណងនៃសំណុំរឿងលេខ០០២ នោះ បានពាក្យសារជាថ្មីដើម្បី ធ្វើជាភាគីនៅក្នុងសំណុំរឿងថ្មី ដូច្នេះហើយឯកសារទាំងអស់ដែលពាក់ព័ន្ធ ទៅនឹងពាក្យសុំទាំងអស់នេះ មាននៅក្នុងសំណុំរឿងលេខ០០២ រួចហើយ។ សហចៅក្រមស៊ើបអង្កេតពិចារណាឃើញថា ចំណុចនេះមានលក្ខណៈគ្រប់គ្រាន់សម្រាប់គោលបំណងនៃកិច្ចស៊ើបសួរបច្ចុប្បន្ន ហើយជាលទ្ធផល បដិសេធសំណើរបស់សហព្រះរាជអាជ្ញាដែលស្នើសុំឲ្យដាក់ឯកសារ D25 ចូលក្នុងសំណុំរឿងលេខ០០២។

៥. ជាចុងក្រោយ ការទទួលខុសត្រូវចំពោះឯកសារ ដែលត្រូវបានដាក់ចូលក្នុងសំណុំរឿងលេខ០០១ ដោយអង្គជំនុំជម្រះសាលាដំបូង បន្ទាប់ពីទទួលបានពីសហចៅក្រមស៊ើបអង្កេតរួចមក និងចាប់តាំងការចាប់ផ្តើមដំណាក់កាលជំនុំជម្រះនៃកិច្ចដំណើរការនីតិវិធីមក គឺជារបស់ក្រឡាបញ្ជី នៃអង្គជំនុំជម្រះសាលាដំបូងតែឯងប៉ុណ្ណោះ។ អនុលោមតាមវិធាន៦៩(២) នៃវិធានផ្ទៃក្នុង នៅពេលបញ្ជូនសំណុំរឿងទៅអង្គជំនុំជម្រះសាលាដំបូង សំណុំរឿងត្រូវបានបោះត្រាដោយក្រឡាបញ្ជីរបស់សហចៅក្រមស៊ើបអង្កេត ដែលនៅដំណាក់កាលនេះ លែងជាអ្នកទទួលខុសត្រូវខ្លឹមសារ នៃសំណុំរឿងទៀតទៀតហើយ។

[4] របាយការណ៍ដែលបញ្ចូលអង្គភាពជនរងគ្រោះ ទម្រង់បែបបទពត៌មានផ្ទាល់ខ្លួនរបស់ដើមបណ្តឹងរដ្ឋប្បវេណី ឯកសារគាំទ្រដើម្បីធ្វើជាទម្រង់បែបបទ លិខិតប្រគល់សិទ្ធិ ជាដើម។

៦. ហេតុដូច្នេះ សហព្រះរាជអាជ្ញាមានភាពត្រឹមត្រូវ នៅពេលដែលពួកគាត់បានលើកឡើងថា ដើម្បីឲ្យមានប្រសិទ្ធភាពទៅលើសំណើសុំរបស់ខ្លួន ការយល់ព្រមរបស់អង្គជំនុំជម្រះសាលាដំបូងគឺជាការចាំបាច់[5]។ ការលើកឡើងនេះកាន់តែត្រឹមត្រូវទៅទៀត ប្រសិនបើចំនួននៃឯកសារខ្លះដែលបានដាក់នៅក្នុងសំណុំរឿងលេខ០០១ ដោយអង្គជំនុំជម្រះសាលាដំបូង ត្រូវបានចាត់ចំណាត់ថ្នាក់ជា "ឯកសារសម្ងាត់" ឬជា "ឯកសារសម្ងាត់បំផុត" នោះសហចៅក្រមស៊ើបអង្កេតក៏មិនអាចបើកមើលបានឡើយ។

៧. បន្ទាប់ពីបានធ្វើការពិចារណាទៅលើបញ្ហាទាំងអស់នេះរួចមក យ៉ាងណាក៏ដោយ សហចៅក្រមស៊ើបអង្កេតបានឯកភាពជាមួយសហព្រះរាជអាជ្ញាថា ភស្តុតាងដែលត្រូវបានបង្ហាញនៅពេលសវនាការ នៅក្នុងសំណុំរឿងលេខ០០១ នឹងមានភាពពាក់ព័ន្ធផ្ទាល់ទៅនឹងការជួយឲ្យស្វែងរកឃើញនូវការពិតនៅក្នុងសំណុំរឿងលេខ០០២។ អាស្រ័យហេតុនេះ សហចៅក្រមស៊ើបអង្កេតយល់ព្រមតាមសំណើរបស់សហព្រះរាជអាជ្ញាជាបណ្តោះអាសន្ន ចំពោះចំណុចដែលថា ឯកសារសំខាន់ៗដែលបានដាក់នៅក្នុងសំណុំរឿងលេខ០០១ ដោយអង្គជំនុំជម្រះសាលាដំបូង ត្រូវដាក់ចូលក្នុងសំណុំរឿងលេខ០០២ ផងដែរ។

៨. ការឯកភាពដោយសហចៅក្រមស៊ើបអង្កេតនេះ មានលក្ខណៈបណ្តោះអាសន្ន អាស្រ័យលើការយល់ព្រមរបស់អង្គជំនុំជម្រះសាលាដំបូង។ ដើម្បីបន្តនីតិវិធីនេះទៅមុខទៀត លិខិតមួយច្បាប់នឹងត្រូវបានផ្ញើជូនទៅលោកប្រធានអង្គជំនុំជម្រះសាលាដំបូង ដោយស្នើសុំការយល់ព្រម និងសុំជំនួយលើបញ្ហានេះ។

**ហេតុដូច្នេះ សហចៅក្រមស៊ើបអង្កេតសម្រេច**

- **យល់ព្រមមួយផ្នែក**តាមសំណើរបស់សហព្រះរាជអាជ្ញា ក្នុងការដាក់ឯកសារសំខាន់ៗ ទាំងអស់ដែលមាននៅក្នុងសំណុំរឿងលេខ០០១ ចូលក្នុងសំណុំរឿងលេខ០០២ ហើយថា ការសម្រេចនេះត្រូវអនុវត្តចំពោះឯកសារដែលបានដាក់នៅក្នុងសំណុំរឿងលេខ០០១ដោយអង្គជំនុំជម្រះសាលា

[5] សំណើ - កថាខណ្ឌទី៩។

ដំបូង បន្ទាប់ពីការបញ្ជូនសំណុំរឿងលេខ០០១ ដោយសហចៅក្រមស៊ើបអង្កេត។ ការយល់ព្រមមួយផ្នែកនេះ នៅតែអាស្រ័យទៅលើការសម្រេចយល់ព្រមពីសំណាក់អង្គជំនុំជម្រះសាលាដំបូង។

- **បដិសេធ**ផ្នែកដែលនៅសល់ផ្សេងៗទៀតនៃសំណើរបស់សហព្រះរាជអាជ្ញា។

ធ្វើនៅភ្នំពេញ ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០០៩

**សហចៅក្រមស៊ើបអង្កេត**

**Co-Investigating Judges**

**Co-juges d'instruction**

**Marcel LEMONDE** យូ ប៊ុនឡេង